សៀមរាប ថ្ងៃទី១២-១៤ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# សិក្ខាសាលាថ្នាក់តំបន់ស្តីពីការពង្រឹងរដ្ឋបាលសារពើពន្ធ លើផលិតផលថ្នាំជក់ សម្រាប់ប្រទេសអាស៊ាន



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ឯកឧត្តម **អ៊ុំ សីហា** អគ្គនាយករងនៃ អគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានធ្វើជាអធិបតីក្នុងពិធីបើក និងបិទសិក្ខាសាលាថ្នាក់តំបន់ស្តីពីការពង្រឹងរដ្ឋបាលសារពើពន្ធ លើផលិតផលថ្នាំជក់ សម្រាប់ប្រទេសអាស៊ានទាំង៥គឺ៖ កម្ពុជា វៀតណាម ឡាវ ភូមា និងឥណ្ឌូនេស៊ី នាថ្ងៃទី១២ ដល់ ១៤ ខែកក្កដា ឆ្នាំ២០១៧ នៅខេត្តសៀមរាប។

សិក្ខាសាលានេះ រៀបចំឡើងដោយមានការសហការជាមួយអង្គការសុខភាពពិភពលោក (WHO) និងអង្គការ Southeast Asia Tobacco Control Alliance (SEATCA)។

សិក្ខាសាលានេះ ក៏មានការអ្នកចូលរួមក្នុង និងក្រៅប្រទេសសរុបប្រមាណ ៧០នាក់ដូចជា៖ លោកអនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ប្រធាន និងអនុប្រធានការិយាល័យ និងមន្ត្រីការិយាល័យ គ្រប់គ្រងអាករពិសេស នៃអគ្គនាយកដ្ឋានពន្ធដារ, តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, តំណាងអង្គការសុខភាពពិភពលោក ប្រចាំកម្ពុជា, ប្រធានអង្គការ SEATCA និងមន្ត្រីពន្ធមកពីប្រទេសឥណ្ឌូនេស៊ី ឡាវ ភូមា និងវៀតណាម។ បន្ថែមពីនេះក៏មានការចូលរួមពីអ្នកជំនាញការមកពី World Bank, ស្នាក់ការកណ្តាល នៃអង្គការសុខភាពពិភពលោក, ពីសាកលវិទ្យាល័យ Cape Town, ពីប្រទេសថៃឡង់, ប្រទេសម៉ាឡេស៊ី, ប្រទេសសិង្ហបុរី និងប្រទេសហ្វីលីពីន។



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

សិក្ខាសាលាថ្នាក់តំបន់អាស៊ាននេះ រៀបចំឡើងក្នុងគោលបំណង៖ ១). ពង្រឹង និងបង្កើនការប្រមូលពន្ធលើបារីស្របតាមមាត្រា៦ (តម្លៃ និងពន្ធលើបារី) នៃអនុសញ្ញាត្រួតពិនិត្យថ្នាំជក់របស់អង្គការសុខភាពពិភពលោក (WHO Framework Convention of Tobacco Control- WHO FCTC)។ ផ្អែកតាមស្ថិតិពី WHO ការជក់បារី ធ្វើឱ្យប្រជាជនលើពិភពលោកស្លាប់ចំនួន ៧,២លាននាក់ជារៀងរាល់ឆ្នាំ។ នៅកម្ពុជា ប្រជាជនស្លាប់ជាង ១ម៉ឺននាក់ ជារៀងរាល់ឆ្នាំ ឬជាង៣០នាក់ ស្លាប់ជារៀងរាល់ថ្ងៃ។ ២).មកដល់ពេលនេះ អនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់(បារី) WHO FCTC មានប្រទេសចំនួន ១៨២/១៩២ ប្រទេសបានចុះហត្ថលេខាចូលរួមរួចហើយ។ កម្ពុជាបានអនុម័តចូលជាសមាជិក ពីខែធ្នូ ២០០៥ កន្លងមក។ ៣). ស្របតាមមាត្រា៦ នៃ WHO FCTC ការតម្លើងពន្ធលើបារីធ្វើឱ្យបារីឡើងថ្លៃ ធ្វើឱ្យប្រជាជនបន្ថយការជក់បារីជួយជីវិតមនុស្ស បង្កើនចំណូលពន្ធជូនពន្ធដារផងដែរ។ ៤).ការបង្កើនចំណូល ពន្ធលើបារី តាមរយៈក្រុមហ៊ុនផលិតបារីត្រូវបង់ពន្ធត្រឹមត្រូវតាមច្បាប់ពន្ធដារ៖ តម្លៃលក់, បរិមាណលក់។ ៥).ផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៏របស់ប្រទេសទាំង៥ រួមទាំងអ្នកជំនាញពីប្រទេសផ្សេងៗលើ៖ អត្រាពន្ធ, ពន្ធតែមប្រ៊ី, ការផ្តល់ការអនុញ្ញាត (License), ការលក់រួចពន្ធ (Duty Free Shop), ដើម្បីស្វែងរកចំណុះខ្វះខាត និងមានវិធានការកែលម្អបន្តលើការប្រមូលពន្ធលើបារីនៅពេលខាងមុខទៀត៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ